**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ ៖០៦៤០អសប

ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦

**សូមជម្រាបជូន**

**ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ**៖ ការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់លើកទី១ មានចំនួន៧៥.៦២០.១៧០.០០០ រៀលគត់ (ចិតសិបប្រាំពាន់ ប្រាំមួយរយម្ភៃលាន មួយរយចិតសិបពាន់រៀលគត់) ទៅក្នុងគណនីប្រាក់បញ្ញើឃុំ សង្កាត់នៅតាមរតនាគាររាជធានី ខេត្តទូទាំងប្រទេស។

**យោង** ៖
- អនុក្រឹត្យលេខ១៦ អនក្រ.បក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យលេខ៤៦៥ អនក្រ.បក. ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់
- លិខិតលេខ៥២២៣សហវ.អហក ៥២២៤សហវ.អហក និង៥២២៥សហវ.អហក.ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ទូទាំងប្រទេសសម្រាប់ឆ្នាំ២០១៦
- អាណត្តិបើកប្រាក់លេខ០០២៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឧបត្ថម្ភមូលនិធិឃុំ សង្កាត់សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ធនធានមូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០១៦ ត្រូវបានធ្វើការវិភាជន៍ពីថវិការបស់រដ្ឋាភិបាលជូនដល់ឃុំ សង្កាត់នៅទូទាំងប្រទេសសរុបចំនួន៣០៨.៤១០.០០០.០០០ រៀលគត់ (បីរយប្រាំបីពាន់ បួនរយដប់លានរៀលគត់)។ ទន្ទឹមនេះ សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញអាណត្តិបើកប្រាក់ចំនួន៧៧.១០០.០០០.០០០ រៀលគត់ (ចិតសិបប្រាំពីរពាន់ មួយរយលានរៀលគត់) ដើម្បីឧបត្ថម្ភជូនដល់មូលនិធិឃុំ សង្កាត់ក្នុងការងាររដ្ឋបាល និងអភិវឌ្ឍន៍។ ផ្អែកលើអាណត្តិបើកប្រាក់ ក្រសួងមហាផ្ទៃបានសម្រេចធ្វើការវិភាជន៍មូលនិធិចំនួន៧៥.៦២០.១៧០.០០០ រៀលគត់ (ចិតសិបប្រាំពាន់ ប្រាំមួយរយម្ភៃលាន មួយរយចិតសិបពាន់រៀលគត់) ទៅឱ្យឃុំ សង្កាត់ទូទាំងប្រទេសសម្រាប់ដំណើរការការងាររដ្ឋបាលចំនួន២៥% និងការងារអភិវឌ្ឍន៍ចំនួន២៤ %។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាផ្ទេរធនធានមូលនិធិឃុំ សង្កាត់តាមចំនួនដូចបានកំណត់ខាងលើទៅក្នុងគណនីប្រាក់បញ្ញើឃុំ សង្កាត់នៅតាមរតនាគាររាជធានី ខេត្តទូទាំងប្រទេសតាមការគួរ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានពីខ្ញុំ។

សូមភ្ជាប់ជាមួយនូវតារាងវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់សម្រាប់រាជធានី ខេត្តចំនួន០២ច្បាប់។

**អគ្គនាយក**

**ម្នាក់ សិទ្ធឿន**

ចម្លងជូន៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប
  ដើម្បីជូនជ្រាប
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២២២៧ សហវ.អគ

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៦

## ជម្រាបជូន

## ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ

**កម្មវត្ថុ:** ការផ្ទេរធនធានមូលនិធិសម្រាប់ចំណាយឧបត្ថម្ភតុល្យភាពថវិកាជូនរដ្ឋបាលក្រុង ស្រុកសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦ ចំនួន **២៤.៦៩២ លានរៀល (ម្ភៃបួនពាន់ ប្រាំមួយរយកៅសិបពីរលានរៀលគត់)** ទៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក។

**យោង:** សារាចរណែនាំលេខ ០១៧ សហវ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ភ្ជាប់ជូន:** តារាងបែងចែកឧបត្ថម្ភធនសម្រាប់រដ្ឋបាលក្រុង ស្រុក នីមួយៗ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា៖ដើម្បីឧបត្ថម្ភតុល្យភាពថវិកាជូនរដ្ឋបាលក្រុង ស្រុកសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦ ក្នុងនាមជាម្ចាស់គណនីមូលនិធិ ក្រុង ស្រុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមស្នើផ្ទេរធនធានចំនួន **២៤.៦៩២ លានរៀល (ម្ភៃបួនពាន់ ប្រាំមួយរយកៅសិបពីរលានរៀលគត់)** ពីមូលនិធិក្រុង ស្រុកជូនរដ្ឋបាលក្រុង ស្រុក ទៅតាមចំនួនដូចមានក្នុងតារាងភ្ជាប់មកជាមួយនេះ។

អាស្រ័យហេតុនេះសូម ឯកឧត្តមមេត្តាផ្ទេរធនធានពីមូលនិធិក្រុង ស្រុក តាមចំនួនសរុបដូចដែលបានស្នើខាងលើទៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុកតាមការគួរ។

សូមឯកឧត្តមអគ្គនាយកទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

**បណ្ឌិត ជុំ គឹមឡេង**

ចម្លងជូន:
-ក្រសួងមហាផ្ទៃ
ដើម្បីជូនជ្រាប

ផ្ទះលេខ ៦០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
No 60, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA